# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការរំឭកបន្ថែមអំពីវិធានការបង្ការ ជំងឺកូវីដ១៩ នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន

ដើម្បីបង្កើនការយកចិត្តទុកដាក់ និងពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាល ជំងឺកូវីដ១៩ នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមរំឭកសារជាថ្មីម្តងទៀតដល់ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ជាពិសេសរោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ត្រូវបន្តអនុវត្តឱ្យបានត្រឹមត្រូវតាមសេចក្តីណែនាំរបស់ក្រសួង លេខ ០០៤/២០ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិធានការបង្ការជំងឺកូវីដ១៩ នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន, និងតាមសេចក្តីណែនាំនានារបស់ក្រសួងសុខាភិបាលពាក់ព័ន្ធនឹងវិធានការបង្ការនិងទប់ស្កាត់ ជំងឺកូវីដ១៩ ជាពិសេសត្រូវៈ

១. ចាត់ចែងឱ្យមានអ្នករដ្ឋបាល ឬអ្នកគ្រប់គ្រងចំនួន ២នាក់ ឬប្រគល់សិទ្ធិដល់គណៈកម្មការសុខភាព និងសុវត្ថិភាពនៅកន្លែងការងារ (OSH Committee) ឬគណៈកម្មការអេដស៍ និងគ្រឿងញៀន របស់រោងចក្រខ្លួនឱ្យធ្វើការផ្សព្វផ្សាយ ណែនាំ ជាប្រចាំដល់កម្មករនិយោជិត អំពីវិធានអនាម័យ សុវត្ថិភាព និងសុខភាពការងារ ជាពិសេសវិធានការបង្ការជំងឺកូវីដ១៩ នៅរៀងរាល់ថ្ងៃសៅរ៍ ឬច្រើនជាងនេះ រហូតដល់ករណីជំងឺកូវីដ១៩ ត្រូវបានបញ្ចប់។

២. គ្រប់គ្រង តាមដាន កត់ត្រា និងតម្កល់ឱ្យបានល្អជាប្រចាំថ្ងៃអំពីការអនុវត្តនូវវិធានការបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ ដើម្បីផ្តល់ជូនអាជ្ញាធរក្នុងករណីចាំបាច់។

៣. រៀបចំឱ្យមានទឹកអាល់កុល ឬជែលលាងដៃ ឬសាប៊ូលាងដៃនៅតាមមាត់ច្រកចេញចូលអគារ សម្រាប់កម្មករនិយោជិតលាងសំអាតដៃមុនពេលចូលក្នុងរោងចក្រ សហគ្រាស គ្រឹះស្ថាន។

៤. រៀបចំឱ្យមានការវាស់កម្តៅគ្រប់បុគ្គលទាំងអស់ មុនពេលអនុញ្ញាតឱ្យចូលក្នុងបរិវេណរោងចក្រ សហគ្រាស គ្រឹះស្ថាន ជាពិសេសអគារផលិតកម្ម និងត្រូវអនុញ្ញាតឱ្យកម្មករនិយោជិតទៅពិគ្រោះយោបល់ជាមួយពេទ្យ ឬអ្នកជំនាញប្រសិនកម្មករនិយោជិតណាម្នាក់មានរោគសញ្ញាក្អក ហៀរសំបោរ ឈឺបំពង់ក ពិបាកដកដង្ហើម និងមានកម្តៅខ្លួនលើសពី៣៧,៥អង្សា។

៥. ត្រូវរៀបចំបម្រុងទុកម៉ាសឱ្យបានគ្រប់គ្រាន់ សម្រាប់បើកផ្តល់ដល់កម្មករនិយោជិត តាមវេជ្ជបញ្ជារបស់ពេទ្យអាស្រ័យលើស្ថានភាពសុខភាព និងស្ថានភាពទូទៅរបស់កម្មករនិយោជិតម្នាក់ៗ។

៦. ត្រូវរំឭកកម្មករនិយោជិតនៅពេលដែលក្អក កណ្តាស់ ត្រូវខ្ទប់មាត់ ច្រមុះ ដោយប្រើកន្សែង ក្រមា ឬកែងដៃ រួចបោះចោលក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ បន្ទាប់មកត្រូវលាងសម្អាតដៃនឹងសាប៊ូ ឬទឹកអាល់កុល។

៧. ណែនាំឱ្យអនុវត្តការស្វាគមន៍គ្នា ដោយការលើកដៃសំពះតាមទំនៀមទម្លាប់ខ្មែរ ចៀសវាងការចាប់ដៃ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៨. ណែនាំកម្មករនិយោជិត ដែលទើបត្រឡប់មកពីប្រទេសកំពុងរីករាលដាលខ្លាំងនៃជំងឺកូវីដ១៩ ឬកម្មករនិយោជិត ដែលបានប៉ះពាល់ដោយផ្ទាល់ជាមួយសាច់ញាតិ ដែលកើតជំងឺកូវីដ១៩ ឱ្យរាយការណ៍ជូនរដ្ឋបាលរោងចក្រជាបន្ទាន់ ដើម្បីរាយការណ៍បន្តមកនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចាត់វិធានការបង្ការ ពិនិត្យ និងព្យាបាលទាន់ពេលវេលា។ ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលទើបវិលត្រឡប់មកពីប្រទេសកំពុងរីករាលដាលខ្លាំងនៃជំងឺកូវីដ ១៩ ឬបានប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកជំងឺកូវីដ១៩ ត្រូវដាក់ខ្លួនឱ្យនៅដាច់ឡែកនៅផ្ទះរយៈពេល ១៤ថ្ងៃ មុននឹងមករោងចក្រ សហគ្រាស គ្រឹះស្ថាន។

៩. ចាត់វិធានការរក្សាសីតុណ្ហភាព និងចរន្តខ្យល់នៅក្នុងអគាររោងចក្រ សហគ្រាស គ្រឹះស្ថាន ឱ្យបានល្អត្រឹមត្រូវ ដូចជាស្រោចទឹកលើដំបូលអគារផលិតកម្មឱ្យបានយ៉ាងហោច ២ដងក្នុង១ថ្ងៃ, បើកបង្អួចទ្វារទាំងអស់, បន្ថែមកង្ហារបញ្ចូលខ្យល់ និងទុកដាក់សម្ភារៈ វត្ថុធាតុដើមឱ្យមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

១០. ផ្តល់ទឹកស្អាតសម្រាប់បរិភោគឱ្យបានគ្រប់គ្រាន់ ដល់កម្មករនិយោជិត និងដាស់តឿនកម្មករនិយោជិតឱ្យហូបអាហារដែលឆ្អិនល្អ សម្រាកឱ្យបានគ្រប់គ្រាន់ ព្រមទាំងកុំធ្វើដំណើរទៅកាន់តំបន់ណា ដែលមានផ្ទុះករណីជំងឺកូវីដ១៩ ជាពិសេសជៀសវាងជាដាច់ខាតការប៉ះពាល់ផ្ទាល់ជាមួយអ្នកកើតជំងឺកូវីដ១៩។

១១. រាយការណ៍ទៅលេខទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ឬលេខទូរស័ព្ទណាមួយដែលផ្តល់ដោយក្រសួងសុខាភិបាល ប្រសិនជាមានកម្មករនិយោជិតណាម្នាក់មានកំដៅខ្លួនលើសពី៣៧,៥អង្សា និងមានរោគសញ្ញាមួយយ៉ាងតិច ដូចជាក្អក ហៀរសំបោរ ឈឺបំពង់ក ដង្ហើមខ្លី ឬពិបាកដកដង្ហើម និងមានប្រវត្តិធ្វើដំណើរទៅតំបន់ដែលមានកើតជំងឺកូវីដ១៩ និងបានប៉ះពាល់ជាមួយអ្នកជំងឺកូវីដ១៩ ឬអ្នកស្លាប់ដោយសារជំងឺស្រួចស្រាល់ដោយមិនដឹងពីអត្តសញ្ញាណ ឬប៉ះពាល់ជាមួយសត្វឈឺក្នុងអំឡុងពេល ១៤ថ្ងៃ មុនចេញរោគសញ្ញា ។

១២. បន្ត និងលើកកម្ពស់ទំនាក់ទំនងវិជ្ជាជីវៈល្អ ជាមួយកម្មករនិយោជិត និងត្រូវរួមគ្នាពិភាក្សាប្រកបដោយភាពស្មោះត្រង់ក្នុងការដោះស្រាយបញ្ហា ឬចំណុចប្រឈមដែលកើតឡើងដោយឥទ្ធិពលជំងឺកូវីដ១៩ ដើម្បីបង្កើនជំនឿទុកចិត្តគ្នាទៅវិញទៅមក និងរក្សាបាននូវអត្ថប្រយោជន៍រួមរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។

ក្រសួងសូមថ្លែងអំណរគុណដល់ម្ចាស់រោងចក្រ សហគ្រាស សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ដែលបានចាត់វិធានការបន្ថែមជាវិជ្ជមាននានា នាំឱ្យសម្រេចបាននូវសុវត្ថិភាព និងសុខភាពរបស់កម្មករនិយោជិតនាពេលកន្លងមក។

ក្រសួងក៏សូមថ្លែងអំណរគុណដល់កម្មករនិយោជិត និងអង្គការវិជ្ជាជីវៈទាំងអស់ ដែលរក្សាបាននូវស្មារតីហ្មឹងហ្មរជឿជាក់ទៅលើការវាយតម្លៃសភាពការណ៍ និងកម្រិតហានិភ័យរបស់សកម្មភាពសេដ្ឋកិច្ចណាមួយ ទៅតាមបច្ចេកទេសវិជ្ជសាស្ត្រ (ពេទ្យ) ដោយក្រសួងសុខាភិបាល និងដៃគូពាក់ព័ន្ធ ជាពិសេសអង្គការសុខភាពពិភពលោក។ ក្រសួងសូមកោតសរសើរ និងអរគុណចំពោះការចូលរួមអនុវត្តវិធានការបង្ការជំងឺកូវីដ១៩ ប្រកបដោយស្មារតីយោគយល់ខ្ពស់។

សេចក្តីដូចមានជម្រាបជូនខាងលើសូមម្ចាស់ ឬនាយករោងចក្រ សហគ្រាសគ្រឹះស្ថាន កម្មករនិយោជិត អង្គការវិជ្ជាជីវៈនានា និងសាធារណៈជនទាំងអស់ជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២០*